ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីទំហំសរុប ១៣.៧៦០ ហិកតា ដែលក្នុងនោះកាត់ចេញ ពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ពីព្រៃសម្បទានយូរីសោគរ ពីដីសម្បទានព្រៃឫស្សី ក្រុមហ៊ុន ភាពីម៉ិក ពីដែនជម្រកសត្វព្រៃភ្នំសំកុស និងពីដីសហគមន៍ព្រៃឈើព្រៃក្រឡាច និងភ្នំរូង ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ១២.៥១៣ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២.២១៥ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីភ្នំទំហំ ១.២៤៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅស្រុករុក្ខគិរី និងស្រុកសំឡូត ខេត្តបាត់ដំបង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១២/១០០៣ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០១២
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៩៩៨ ឧបប ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១..**

ត្រូវបានកាត់ដីទំហំសរុប ១៣.៧៦០ ហិកតា ដែលក្នុងនោះកាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ទំហំ ២.៦៤៧,៧៧ ហិកតា ពីព្រៃសម្បទានយូរីសោគរ ទំហំ ៨០៩០,១៣ ហិកតា ពីដីសម្បទានព្រៃឫស្សី ក្រុមហ៊ុន ភាពីម៉ិក ទំហំ ២.៨៧៨,៥ ហិកតា ពីដែនជម្រកសត្វព្រៃភ្នំសំកុស ទំហំ ១០០ ហិកតា និងពីដីសហគមន៍ព្រៃឈើព្រៃត្រឡាច និងភ្នំរូង ទំហំ ៤៣,៦០ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ១២.៥១៣ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីភ្នំទំហំ ១.២៤៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅស្រុករុក្ខគិរី និងស្រុកសំឡូត ខេត្តបាត់ដំបង ដែលមានទំហំ និងស្ថិតនៅក្នុងភូមិសាស្ត្រដូចខាងក្រោម៖

១ ផ្ទៃដីទំហំសរុប ៤.៧៧២ ហិកតា ដែលក្នុងនោះកាត់ចេញពីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋទំហំ ២៦៤៧,៧៧ ហិកតា ពីព្រៃសម្បទានយូរីសោគរទំហំ ២០៨០,៦៣ ហិកតា ពីដីសហគមន៍ព្រៃឈើព្រៃត្រឡាច ទំហំ ៧,៣១ ហិកតា និងពីដីសហគមន៍ព្រៃឈើភ្នំរូង ៣៦,២៩ ហិកតា ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៤.២៧៨ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីភ្នំទំហំ ៤៩៤ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិរូង១ ឃុំព្រៃត្រឡាច ស្រុករុក្ខគិរី តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១) នៃអនុក្រឹត្យនេះ ។

២. ផ្ទៃដីទំហំ ៦.០០៩,៥ ហិកតា កាត់ចេញពីព្រៃសម្បទានយូរីសោគរ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៥.២៥៦,៥ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីភ្នំទំហំ ៧៥៣ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រៃធំ ឃុំកំពុងល្ពៅ ស្រុកសំឡូត តាមប្រព័ន្ធ កូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ ។

៣.ផ្ទៃដីទំហំ ២.៩៧៨.៥ ហិកតា ដែលក្នុងនោះកាត់ចេញពីដីសម្បទានព្រៃឫស្សី ក្រុមហ៊ុន ភាពីម៉ិច ទំហំ ២.៨៧៨,៥ ហិកតា និងពីដែនជម្រកសត្វព្រៃភ្នំសំកុស ទំហំ ១០០ ហិកតា តាមរយៈព្រះរាជក្រឹត្យកាត់ចេញពីព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ភូមិស្ទឹងតូច ឃុំកំពុងល្ពៅ ស្រុកសំឡូត តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (២) នៃអនុក្រឹត្យនេះ។

**មាត្រា ២ ..**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ២.២១៥ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅស្រុករុក្ខគិរី និងស្រុកសំឡូត ខេត្តបាត់ដំបង ដែលមានចំនួនគ្រួសារ និងស្ថិតនៅក្នុងភូមិសាស្ត្រដូចខាងក្រោម៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៨៦២ គ្រួសារ នៅភូមិរូង១ ឃុំព្រៃត្រឡាច ស្រុករុក្ខគិរី
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ១.០៩៧ គ្រួសារ នៅភូមិព្រៃធំ ឃុំកំពុងល្ពៅ ស្រុកសំឡូត
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ២៥៦ គ្រួសារ នៅភូមិ ស្ទឹងតូច ឃុំកំពុងល្ពៅ ស្រុកសំឡូត

**មាត្រា ៣ ..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

**មាត្រា ៤ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ[illegible] ឆ្នាំ ២០១២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ឧបសម្ព័ន្ធ(១) នៃអនុក្រឹត្យលេខ ៧១៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១២ ស្តីពីការកាត់ដីទំហំសរុប ១៣.៧៦០ ហិកតា ដែលនោះកាត់ចេញពីតំបន់ព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ពីព្រៃសម្បទានស៊ីសែអរ ពីដីសម្បទានព្រៃឬស្សី ក្រុមហ៊ុន តាពីនិក ពីដែនជម្រកសត្វព្រៃភ្នំសំកុស និងពីដីសហគមន៍ព្រៃឈើព្រៃក្រញូង និងស្រែ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ១២.៥១៣ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២.២១៥ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះដាក់ស្ថេរ និងដីភ្នំទំហំ ១.២៤៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅស្រុករុក្ខគិរី និងស្រុកសំឡូត ខេត្តបាត់ដំបង




**ប្រព័ន្ធកូអរដោនេ :**

*តំបន់ទី* : 48N

*ចំណោលផែនទី* : UTM

*ទិន្នន័យយោង* : WGS1984

**ប្រភពទិន្នន័យ:**

*ព្រំប្រទល់: នាយកដ្ឋានភូមិសាស្ត្រ*

*គំរបព្រៃ: រដ្ឋបាលព្រៃឈើ ឆ្នាំ ២០០២*



| ចំនុចនិយាមការ | | |
|---|---|---|
| ល.រ | X | Y |
| 1 | 330693 | 1394526 |
| 2 | 330805 | 1392999 |
| 3 | 330373 | 1388721 |
| 4 | 329972 | 1387799 |
| 5 | 328745 | 1387798 |
| 6 | 328142 | 1387131 |
| 7 | 328562 | 1386884 |
| 8 | 330362 | 1385299 |
| 9 | 329718 | 1383326 |
| 10 | 327718 | 1382089 |
| 11 | 326695 | 1383487 |
| 12 | 326159 | 1383704 |
| 13 | 326087 | 1385686 |
| 14 | 326760 | 1386769 |
| 15 | 326303 | 1387052 |
| 16 | 326580 | 1387472 |
| 17 | 324866 | 1387861 |
| 18 | 323345 | 1388125 |
| 19 | 323359 | 1388933 |
| 20 | 324094 | 1389332 |
| 21 | 324386 | 1390729 |
| 22 | 326467 | 1392101 |
| 23 | 327534 | 1391522 |
| 24 | 327898 | 1392350 |
| 25 | 327189 | 1392993 |
| 26 | 330510 | 1394532 |

ឧបសម្ព័ន្ធ(២) នៃអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ស្តីពីការកាត់ដីទំហំសរុប ១៣.៧៦០ ហិកតា ដែលក្នុងនោះកាត់ចេញពីតំបន់ព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍របស់រដ្ឋ ពីព្រៃសម្បទានឈើសោភា ពីដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុន តាគីទិក ពីដែនជម្រកសត្វព្រៃភ្នំសំកុស និងពីដីសហគមន៍ព្រៃឈើព្រៃស្រឡាង និងអូរព្លុង ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ចំនួនផ្ទៃដី ទំហំ ១២.៥១៣ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២.២១៥ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីផ្ទៃទំហំ ១.២៤៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅស្រុកភ្នំព្រឹក និងស្រុកសំឡូត ខេត្តបាត់ដំបង




| ចំនុចនិយាមការ | | |
|---|---|---|
| ល.រ | X | Y |
| 1 | 290997 | 1403079 |
| 2 | 291030 | 1401745 |
| 3 | 292229 | 1401852 |
| 4 | 292185 | 1400796 |
| 5 | 292574 | 1400727 |
| 6 | 292575 | 1400232 |
| 7 | 292960 | 1400190 |
| 8 | 292976 | 1399736 |
| 9 | 292622 | 1398580 |
| 10 | 292773 | 1397761 |
| 11 | 292191 | 1397347 |
| 12 | 292177 | 1397000 |
| 13 | 292000 | 1397000 |
| 14 | 292000 | 1395000 |
| 15 | 288000 | 1395000 |
| 16 | 288075 | 1391690 |
| 17 | 285575 | 1391690 |
| 18 | 285577 | 1394992 |
| 19 | 284303 | 1395276 |
| 20 | 285711 | 1399302 |
| 21 | 286030 | 1400008 |
| 22 | 286628 | 1400181 |
| 23 | 287360 | 1403772 |
| 24 | 288968 | 1403307 |
| 25 | 288850 | 1402879 |
| 26 | 279817 | 1399277 |
| 27 | 279752 | 1391171 |
| 28 | 280812 | 1391243 |
| 29 | 281278 | 1390323 |
| 30 | 280273 | 1389491 |
| 31 | 279214 | 1389171 |
| 32 | 275600 | 1397530 |
| 33 | 275979 | 1399708 |

**ប្រព័ន្ធកូអរដោនេ :**

តំបន់ទី : 48N

ចំណោលផែនទី : UTM

និន្នន័យយោង : WGS1984

**ប្រភពទិន្នន័យ:**

ព្រំប្រទល់: នាយកដ្ឋានភូមិសាស្ត្រ

គំរបព្រៃ: រដ្ឋបាលព្រៃឈើ ឆ្នាំ ២០០២



